## ២

# ការសិក្សាខ្លីៗ
# ទៅលើព្រះគម្ពីរ

ជំហានដំបូងក្នុងការស្វែងយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់

**សៀវភៅសំរាប់សិស្ស**

**សិក្សាជាក្រុម**

សំរាប់**គ្រិស្តបរិស័ទថ្មី**

ធីនអាទ្រៀន
នៃកម្ពុជា

# មាតិកា

សេចក្តីផ្តើម

ជំពូកទី១ ចំណេះដឹងទូទៅអំពីព្រះគម្ពីរ

ក. ប្រវត្តិរបស់ព្រះគម្ពីរ

ខ. ភាពត្រូវត្រារបស់ព្រះគម្ពីរ

គ. ការស្វែងយល់អត្ថន័យព្រះគម្ពីរទាំងមូល (ការបន្តបើកសំដែង)

ឃ. តើព្រះគ្រិស្តមានជាប់ទាក់ទងអ្វីជាមួយនឹងព្រះគម្ពីរ?

ង. របៀបនៃការកំនត់ឆ្នាំ

ជំពូកទី២ របៀបដែលព្រះគម្ពីរបានសរសេរឡើង

ក. ការបំភ្លឺរបស់ព្រះជាម្ចាស់-តើមានអត្ថន័យយ៉ាងដូចម្តេចទៅ?

ខ. តើព្រះជាម្ចាស់បំភ្លឺមនុស្សអោយសរសេរកណ្ឌគម្ពីរឡើងតាមវិធីណា?

គ. របៀបដែលព្រះគម្ពីរបានមកដល់យើង

ជំពូកទី៣ តើយើងដឹងថាព្រះគម្ពីរមានភាពសុក្រឹតដោយរបៀបណា?

ជំពូកទី៤ ការសិក្សាខ្លីៗទៅលើសម្ពន្ធមេត្រីចាស់

ជំពូកទី៥ ការសិក្សាខ្លីៗទៅលើសម្ពន្ធមេត្រីថ្មី

ឯកសារសំរាប់អាន និងសិក្សាបន្ថែម

# សេចក្តីផ្តើម

សព្វថ្ងៃនេះមានមនុស្សកំពុងតែសួរថា "ហេតុអ្វីបានជាត្រូវអានព្រះគម្ពីរ? វាហួសសម័យហើយ ។ ព្រះគម្ពីរត្រូវបានសរសេរឡើង២000ឆ្នាំកន្លងមកហើយ ។ តើព្រះគម្ពីរជួយដោះស្រាយបញ្ហាដែលខ្ញុំកំពុងតែជួបប្រទះយ៉ាងដូចម្តេចបាន?

តើយើងអាចរកឃើញចំលើយសំរាប់សំនួរនេះបានដែរឬទេ?

ព្រះគម្ពីរមានគ្រប់ចំលើយសំរាប់មនុស្សនាពេលបច្ចុប្បន្ន ដែលកំពុងតែមានចំងល់ចំពោះអត្ថន័យ និងគោលដៅសំរាប់ជីវិតរបស់គេ ។ ព្រះគម្ពីរប្រាប់យើងអំពី ប្រវត្តិរបស់មនុស្ស គោលបំណងរបស់មនុស្ស ប្រភពនៃបញ្ហារបស់មនុស្ស ហើយនិងដំណោះស្រាយសំរាប់បញ្ហាទាំងអស់នោះ ។ ព្រះគម្ពីរក៏បានប្រាប់ផងដែរអំពី វិធីរស់នៅដែលល្អជាងគេ ។

នៅក្នុងវគ្គសិក្សានេះ យើងនឹងសិក្សាខ្លីៗទៅលើព្រះគម្ពីរទាំងមូល ។ តើព្រះគម្ពីរនិយាយអំពីអ្វី? នរណាជាអ្នកនិពន្ធ? តើព្រះគម្ពីរបានមកដល់យើងសព្វថ្ងៃនេះដោយរបៀបណា?

លំហាត់ដែលមាននៅក្នុងសៀវភៅលំហាត់សំរាប់វគ្គនេះ ត្រូវបានរៀបចំឡើងដើម្បីនាំបងប្អូនចូលទៅមើលអោយឃើញច្បាស់អំពីខ្លឹមសារនៃព្រះគម្ពីរសម្ពន្ធមេត្រីចាស់ និងសម្ពន្ធមេត្រីថ្មី ។

បងប្អូនគួរតែអានកូនសៀវភៅមួយដែលមានចំណងជើងថា ***យល់ដឹងពីព្រះគម្ពីររបស់ខ្លួន*** និពន្ធដោយ ដាវីឌ ហ្វេន សំរាប់ចំណេះដឹងបន្ថែមនៅក្នុងវគ្គសិក្សានេះ ។ សៀវភៅ *យល់ដឹងពីព្រះគម្ពីររបស់ខ្លួន* មានអត្ថបទសង្ខេបមួយដ៏ល្អ ( ប្រហែលមួយកថាកណ្ឌ) សំរាប់កណ្ឌគម្ពីរទាំង៦៦ នៅក្នុងព្រះគម្ពីរ ។

# ជំពូកទី១

## ចំណេះដឹងទូទៅអំពីព្រះគម្ពីរ

### ក. ប្រវត្តិរបស់ព្រះគម្ពីរ

**១. តើមានកណ្ឌគម្ពីរប៉ុន្មាននៅក្នុងព្រះគម្ពីរ?**

សម្ពន្ធមេត្រីចាស់មាន៣៩កណ្ឌ

សម្ពន្ធមេត្រីថ្មីមាន២៧កណ្ឌ

ព្រះគម្ពីរទាំងមូលមានទាំងអស់៦៦កណ្ឌ

**២. តើមនុស្សប៉ុន្មាននាក់ជាអ្នកសរសេរកណ្ឌគម្ពីរទាំង៦៦នោះ?**

ប្រហែលជាមានមនុស្ស៤០នាក់ជាអ្នកសរសេរកណ្ឌគម្ពីរទាំងអស់នៅក្នុងព្រះគម្ពីរ ។ ពួកគាត់មានជីវប្រវត្តិផ្សេងៗពីគ្នា ។ អ្នកខ្លះជាកសិករ ខ្លះជាក្សត្រ ខ្លះអ្នកនេសាទ ខ្លះបេសកជន ខ្លះវេជ្ជបណ្ឌិត ខ្លះជាអ្នកអធិប្បាយព្រះបន្ទូល ខ្លះជាអ្នកគង្វាល និងខ្លះទៀតជាមន្ត្រីរាជការ ។

**៣. តើចំណាយអស់រយៈពេលប៉ុន្មានទៅ ក្នុងការសរសេរព្រះគម្ពីរទាំងមូល?**

ព្រះគម្ពីរបានសរសេរឡើងនៅក្នុងកំឡុងពេលប្រហែលជាជាង១៥០០ឆ្នាំ ។ កណ្ឌដែលបានសរសេរមុនគេនោះគឺ កណ្ឌគម្ពីរយ៉ូប ។ កណ្ឌគម្ពីរនេះប្រហែលជានិពន្ធឡើងច្រើនជាង១៥០០ឆ្នាំមុនគ្រិស្តសករាជ ។ កណ្ឌគម្ពីរដែលនិពន្ធក្រោយគេបង្អស់ប្រហែលជាកណ្ឌគម្ពីរវិវរណៈ ។ កណ្ឌនេះបាននិពន្ធឡើងក្នុងកំឡុងឆ្នាំ១០០នៃគ្រិស្តសករាជ ។ កណ្ឌគម្ពីរទាំងឡាយនៅក្នុងសម្ពន្ធមេត្រីថ្មីត្រូវបាននិពន្ធឡើងនៅសតវត្សទី១នៃគ្រិស្តសករាជ (ចន្លោះឆ្នាំ១ដល់ឆ្នាំ១០០នៃគ្រិស្តសករាជ) ។

**៤. តើព្រះគម្ពីរសរសេរឡើងជាភាសាអ្វី?**

ព្រះគម្ពីរសម្ពន្ធមេត្រីចាស់បានសរសេរឡើងជាភាសាហេប្រឺ ។ មានផ្នែកខ្លះនៃសម្ពន្ធមេត្រីចាស់បានសរសេរឡើងជាភាសាអារ៉ាមិក ។

ព្រះគម្ពីរសម្ពន្ធមេត្រីថ្មីបានសរសេរឡើងជាភាសាក្រិក ។

ព្រះគម្ពីរសម្ពន្ធមេត្រីចាស់បានសរសេរឡើងជាភាសាហេប្រឺ ដោយសារតែកាលពីសម័យនោះ ភាសាហេប្រឺជាភាសាដែលមនុស្សនៅតំបន់នោះប្រើប្រាស់ប្រចាំថ្ងៃ ។

ប៉ុន្តែនៅសម័យដែលគេសរសេរសម្ពន្ធមេត្រីថ្មីវិញ មនុស្សភាគច្រើននៅតំបន់នោះមិននិយាយភាសាហេប្រឺទេ តែពួកគេនិយាយភាសាក្រិក ។ នេះជាមូលហេតុដែលគេសរសេរសម្ពន្ធមេត្រីថ្មីជាភាសាក្រិក ។

### ខ. ភាពត្រូវគ្នារបស់ព្រះគម្ពីរ

ភាពអស្ចារ្យមួយរបស់ព្រះគម្ពីរនោះគឺ កណ្ឌគម្ពីរទាំង៦៦ដើរស្របគ្នា និងមានភាពត្រូវគ្នាទៀតផង ។ ភាពត្រូវគ្នារបស់ព្រះគម្ពីរបានពន្យល់យើងយ៉ាងច្បាស់ថា ព្រះជាម្ចាស់ទើបជាអ្នកនិពន្ធព្រះគម្ពីរដោយផ្ទាល់ ។ ព្រះអង្គជាអ្នកដឹកនាំ និងបំភ្លឺមនុស្សផ្សេងៗពីគ្នាអោយសរសេរព្រះគម្ពីរឡើង ។

កំណ្ឌគម្ពីទាំង៦៦បានផ្តល់អោយយើងយ៉ាងពេញលេញនូវព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលព្រះអង្គចង់មានបន្ទូលមកកាន់យើង ។ នៅក្នុងព្រះគម្ពីរមានចែងប្រាប់យើងនូវចំណេះដឹងជាច្រើនដូចជា របៀបក្លាយជាគ្រិស្តបរិស័ទ និងរបៀបរស់នៅជាគ្រិស្តបរិស័ទដែលមានជោគជ័យជាដើម ។

## គ. ការស្វែងយល់អត្ថន័យព្រះគម្ពីរទាំងមូល (ការបន្តបើកសំដែង)

ប្រសិនបើបងប្អូនចង់យល់ដឹងអោយបានច្បាស់ចំពោះការបង្រៀនរបស់ព្រះគម្ពីរ បងប្អូនចាំបាច់ត្រូវតែស្វែងយល់អត្ថន័យនៃព្រះគម្ពីរទាំងមូលជាមុនសិន ។ បែបនេះទើបមានភាពងាយស្រួលក្នុងការដកស្រង់ខគម្ពីរពីព្រះគម្ពីរ ដើម្បីយកមកគាំទ្រដល់ការបង្រៀនរបស់បងប្អូន ។ ឧទាហរណ៍ដូចជានៅក្នុង ទំនុកតម្កើង១៤:១បានចែងថា "... គ្មានព្រះជាម្ចាស់ទាល់តែសោះ!" ។ ប៉ុន្តែមានខគម្ពីរជាច្រើនទៀតនៅក្នុងព្រះគម្ពីរ (ចាប់ពីលោកុប្បត្តិ១:១ទៅ) បានបញ្ជាក់យ៉ាងច្បាស់ថា ពិតជាមានព្រះជាម្ចាស់មែន ។

ទំនុកតម្កើង១៤:១មិនបានប្រឆាំងឡើយ ជាមួយនឹងខគម្ពីរផ្សេងទៀតដែលបង្រៀនថា ពិតជាមានព្រះជាម្ចាស់ ។ បញ្ហារបស់យើងនោះគឺ យើងមិនបានស្វែងយល់ព្រះគម្ពីរទាំងមូល ។ យើងមិនអានខគម្ពីរនោះអោយចប់ ។ បើអានអោយចប់ខគម្ពីរនោះទាំងមូល ទើបយើងអាចយល់អត្ថន័យពិតដែលមាននៅក្នុងនោះ ។ ទំនុកតម្កើង១៤:១បានចែងថា "មនុស្សល្ងីល្ងើគិតក្នុងចិត្តថា គ្មានព្រះជាម្ចាស់ទាល់តែសោះ!" ។

យើងត្រូវតែមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការសន្មតគ្រប់ប្រធានបទទាំងឡាយ ដែលមានចែងនៅក្នុងព្រះគម្ពីរ ។ ពិតជាសំខាន់ក្នុងការអានកំណ្ឌគម្ពីរនិមួយៗ ជំពូកនិមួយៗ និងខនិមួយៗដែលមានទំនាក់ទំនងគ្នានៅក្នុងព្រះគម្ពីរទាំងមូល ។

ព្រះគម្ពីរបានសរសេរឡើងនៅក្នុងកំឡុងពេលប្រហែលជាជាង១៥០០ឆ្នាំ ។ ពេលវេលាចេះកន្លងផុតទៅ ព្រះជាម្ចាស់ក៏បានបន្តបើកសំដែងអោយយើងឃើញថែមទៀតអំពីព្រះអង្គផ្ទាល់ និងរបៀបរស់នៅរបស់យើង ដែលគាប់ព្រះហឫទ័យព្រះអង្គ ។ កំណ្ឌគម្ពីរទាំងឡាយនៅក្នុងព្រះគម្ពីរបានចែងប្រាប់យើងជាបន្តបន្ទាប់អំពីព្រះជាម្ចាស់ ។

ដូចគ្នាដែរ ចំពោះដំណោះស្រាយជាច្រើនដែលសំខាន់សំរាប់យើង ក៏មានចែង និងពន្យល់នៅក្នុងព្រះគម្ពីរដែរ ។ ការបើកសំដែងដល់មនុស្សបែបនេះ ពីជំនាន់មួយទៅជំនាន់មួយទៀត គេហៅថា "ការបន្តបើកសំដែង" ។

## ឃ. តើព្រះគ្រិស្តមានជាប់ទាក់ទងអ្វីជាមួយនឹងព្រះគម្ពីរ?

ព្រះយេស៊ូគ្រិស្តជាមនុស្សដ៏សំខាន់នៅក្នុងព្រះគម្ពីរ ។ ព្រះគម្ពីរទាំងមូលបានផ្តោតទៅលើជីវិតរបស់គ្រិស្ត ។ ព្រះគម្ពីរសម្ពន្ធមេត្រីចាស់បានថ្លែងអំពីការមកដល់របស់ព្រះយេស៊ូ ។ ព្រះអង្គគឺជាព្រះសង្គ្រោះដែលនាំសេរីភាពមកអោយយើង ដើម្បីអោយយើងបានរួចផុតពីអំពើបាប (ការសង្គ្រោះ) ។

ព្រះគម្ពីរសម្ពន្ធមេត្រីថ្មីបានសរសេរឡើងបន្ទាប់ពីព្រះយេស៊ូយាងត្រឡប់ទៅស្ថានបរមសុខវិញ ។ កំណ្ឌគម្ពីរនៅក្នុងសម្ពន្ធមេត្រីថ្មីបានរៀបរាប់អំពីកិច្ចការដែលព្រះយេស៊ូបានបំពេញនៅលើផែនដី និងការត្រៀមខ្លួនសំរាប់យាងត្រឡប់ជាលើកទី២របស់ព្រះគ្រិស្ត ។

ហេតុការណ៍ដែលសំខាន់ជាងគេ ហើយបានសរសេរទុកនៅក្នុងព្រះគម្ពីរនោះគឺ ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ ។ ព្រះអង្គបានយាងមកផែនដី ហើយរស់នៅដូចមនុស្សទូទៅ ។ ព្រះអង្គបានបង្រៀនយើង និងបង្ហាញយើងអំពីរបៀបរស់ជីវិតជាគ្រិស្តបរិស័ទ ។ បន្ទាប់មកព្រះអង្គបានសុគតដើម្បីលោះអំពើបាបរបស់យើង ។ ប៉ុន្តែចំនុចដែលសំខាន់ជាងគេនោះគឺ ព្រះអង្គមានព្រះជន្មរស់ឡើងវិញ ។ យើងទាំងអស់គ្នាមានឱកាសក្នុងការបំរើព្រះដែលមានព្រះជន្មគង់នៅ ។ ព្រះអង្គមិនស្លាប់ទេ ។

## ង. របៀបនៃការកំនត់ឆ្នាំ

នៅសម័យដែលគេនិពន្ធព្រះគម្ពីរ  គេមិនកំនត់ឆ្នាំដូចការកំនត់ដែលយើងកំនត់នាពេលបច្ចុប្បន្នទេ។ មានប្រទេសជាច្រើនរាប់ឆ្នាំតាមការគ្រងរាជថ្មីរបស់ព្រះមហាក្សត្រ។ ហើយពេលខ្លះគេកំនត់ឆ្នាំតាមព្រឹត្តិការណ៍ធំដែលបានកើតមានឡើង។

យើងមានឧទាហរណ៍មួយនៅក្នុងសម្ពន្ធមេត្រីចាស់ ក្នុងរជ្ជកាលព្រះបាទសាឡូម៉ូន។ ១ពង្សាវតារក្សត្រ៦:១បានចែងថា "ព្រះបាទសាឡូម៉ូនបានសង់ព្រះតំណាក់ថ្វាយព្រះអម្ចាស់ នៅឆ្នាំទីបួនរយប៉ែតសិប ក្រោយពេលកូនចៅអ៊ីស្រាអែលចាកចេញពីស្រុកអេស៊ីប គឺនៅឆ្នាំទីបួននៃរជ្ជកាលព្រះបាទសាឡូម៉ូន. . ." ។ តាមរយៈខគម្ពីរនេះបានបញ្ជាក់ថា ការកំនត់ឆ្នាំតាមវិធីទាំងពីរដូចបានរៀបរាប់ខាងលើ ត្រូវបានគេយកមកប្រើនៅប្រទេសអ៊ីស្រាអែលនាសម័យនោះ។ ការកំនត់ឆ្នាំរបស់ប្រទេសមួយមានលក្ខណៈខុសពីការកំនត់ឆ្នាំរបស់ប្រទេសផ្សេងមួយទៀត។

មកទល់នឹងរាប់រយឆ្នាំក្រោយកំណើតព្រះយេស៊ូ  ទើបមានការកំនត់ឆ្នាំដូចនាពេលបច្ចុប្បន្ន។ មានប្រទេសស្ទើរតែទាំងអស់នៅលើពិភពលោកបានកំនត់ឆ្នាំដូចពេលបច្ចុប្បន្ននេះ។

ឆ្នាំ១៩៩៥មានន័យថា ១៩៩៥ឆ្នាំបន្ទាប់ពីកំណើតរបស់ព្រះគ្រិស្ត។ ឆ្នាំដែលនៅខាងមុខកំណើតរបស់ព្រះគ្រិស្ត ត្រូវបានគេរាប់បញ្ច្រាស់ទៅក្រោយវិញ។ ឧទាហរណ៍ដូចជាកណ្ឌគម្ពីរម៉ាឡាគី បានសរសេរឡើងប្រហែលជា៤០០ឆ្នាំមុនគ្រិស្តសករាជ ឬយើងអាចនិយាយបានថា ៤០០ឆ្នាំមុនកំណើតរបស់ព្រះគ្រិស្ត។ លោកម៉ូសេសរសេរកណ្ឌគម្ពីរលោកុប្បត្តិប្រហែលជា១៥០០ឆ្នាំមុនគ្រិស្តសករាជ ឬយើងអាចនិយាយថា ១៥០០ឆ្នាំមុនកំណើតរបស់ព្រះគ្រិស្តក៏បាន។

# ជំពូកទី២

# របៀបដែលព្រះគម្ពីរបានសរសេរឡើង

## ក.ការបំភ្លឺរបស់ព្រះជាម្ចាស់-តើមានអត្ថន័យយ៉ាងដូចម្តេចទៅ?

តើវាមានអត្ថន័យយ៉ាងដូចម្តេចទៅនៅពេលដែលយើងនិយាយថា "ព្រះគម្ពីរទទួលនូវការបំភ្លឺពីព្រះជាម្ចាស់"? តើវិធីណាដែលអាចធ្វើអោយយើងយល់អត្ថន័យនៃប្រយោគនេះ? ខគម្ពីរចំនួន៣នៅក្នុងព្រះគម្ពីរមានចែងអំពីចំលើយសំរាប់សំនួរនេះ។
(២ធីម៉ូថេ ៣:១៦ និង ២ពេត្រុស ១:២០-២១)

**២ធីម៉ូថេ ៣:១៦ (ព្រះគម្ពីរបរិសុទ្ធ)**
**"គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឱ្យតែងទេ. . ."**

**២ធីម៉ូថេ ៣:១៦ (ព្រះគម្ពីរជាភាសាខ្មែរបច្ចុប្បន្ន)**
**"គ្រប់អត្ថបទគម្ពីរ សុទ្ធតែព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកបំភ្លឺអោយតែង . . ."**

ខគម្ពីរនេះបញ្ជាក់ប្រាប់យើងអំពីអត្ថន័យនៃ "ការបំភ្លឺរបស់ព្រះជាម្ចាស់" ថា:

១. ព្រះជាម្ចាស់ប្រទានព្រះគម្ពីរអោយយើង។
២. ព្រះអង្គជាអ្នកធ្វើអោយគ្រប់អត្ថបទគម្ពីរទាំងអស់រស់។ មិនមែនងាប់នៅលើតែក្រដាស់សៀវភៅនោះឡើយ។ នៅពេលដែលបងប្អូនយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ មកបញ្ចូលនៅក្នុងជីវិតប្រចាំថ្ងៃរបស់បងប្អូន នោះបងប្អូននឹងឃើញថា ព្រះបន្ទូលរបស់ព្រះអង្គជាព្រះបន្ទូលរស់! ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានជីវិត ហើយព្រះជាម្ចាស់នឹងចាប់ផ្តើមបំផ្លាស់ជីវិតរបស់បងប្អូន!

២ពេត្រុស ១:២០-២១ ប្រាប់យើងនូវចំលើយ២បន្ថែមទៀត ដែលអាចជួយអោយយើងយល់អត្ថន័យនៃ "ការបំភ្លឺរបស់ព្រះជាម្ចាស់"។
៣. គ្មានកំណត់គម្ពីរណាមួយដែលចេញពីបំណងចិត្តរបស់មនុស្សឡើយ។
៤. ព្រះវិញ្ញាណដ៏វិសុទ្ធជំរុញចិត្តព្យាការីទាំងនោះអោយថ្លែងព្រះបន្ទូល (សរសេរចេញមក)។

នៅពេលយើងនិយាយថា "ព្រះគម្ពីរទទួលនូវការបំភ្លឺពីព្រះជាម្ចាស់" យើងចង់មានន័យថា:

**ព្រះវិញ្ញាណជាអ្នកដឹកនាំគំនិតរបស់មនុស្ស ទើបពួកគាត់អាចសរសេរនូវព្រះបន្ទូលដែលគាប់ព្រះទ័យព្រះជាម្ចាស់បាន។**

ជាការសំខាន់ក្នុងការចាំថា ព្រះគម្ពីរទទួលនូវការបំភ្លឺពីព្រះជាម្ចាស់។ កំណត់គម្ពីរទាំងអស់ទទួលនូវការបំភ្លឺដូចៗគ្នា។ គ្មានកំណត់គម្ពីរណាទទួលនូវការបំភ្លឺពីព្រះជាម្ចាស់ច្រើនជាងកំណត់គម្ពីរណាឡើយ។

## ខ. តើព្រះជាម្ចាស់បំភ្លឺមនុស្សអោយសរសេរកណ្ឌគម្ពីរឡើងតាមវិធីណា?

### ១. ព្រះជាម្ចាស់មិនបានមានបន្ទូលពាក្យចំៗអោយមនុស្សសរសេរនោះទេ (ភាគច្រើន)

អ្នកតែងកណ្ឌគម្ពីរទាំងអស់ មិនបានអង្គុយ ហើយក៏មិនបានស្ដាប់ឮព្រះអង្គមានបន្ទូលខ្លាំងៗដែរថា "យើងជាព្រះអម្ចាស់កំពុងមានបន្ទូលៈ អេសាយជំពូកទី៤ ត្រូវសរសេរថា. . ." ។ មានតែប៉ុន្មានលើកតែប៉ុណ្ណោះ ដែលព្រះជាម្ចាស់មានបន្ទូលមកអ្នកតែងនូវពាក្យចំៗ ។ ក្រិត្យវិន័យទាំង១០របស់ព្រះអង្គ ជាឧទាហរណ៏មួយ ។

### ២. ព្រះជាម្ចាស់មិនបានចាប់ដៃអ្នកតែងអោយសរសេរនោះទេ

ព្រះជាម្ចាស់មិនបានសណ្ដំអ្នកតែងទាំងនោះ ហើយដឹកដៃពួកគាត់អោយសរសេរកណ្ឌគម្ពីរទាំងនោះឡើយ ។ ព្រះជាម្ចាស់ក៏មិនបានធ្វើឱ្យពួកគាត់ក្លាយជាមនុស្សយន្តដែរ ។ ពួកគាត់ដឹងខ្លួនច្បាស់ណាស់ ចំពោះកិច្ចការដែលពួកគាត់កំពុងបំពេញ ។

### ៣. ព្រះវិញ្ញាណប្រទានអោយអស់លោកដែលជាអ្នកតែងកណ្ឌគម្ពីរនូវគំនិតក្នុងការសរសេរតាមវិធីរៀងៗខ្លួន

កណ្ឌគម្ពីរនៅក្នុងព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលសរសេរឡើងទៅតាមសិល្បៈវិធីរបស់អ្នកនិពន្ធរៀងៗខ្លួន ។

ព្រះជាម្ចាស់ជ្រើសរើសមនុស្សផ្សេងៗពីគ្នាអោយមកសរសេរកណ្ឌគម្ពីរនៅក្នុងព្រះគម្ពីរទាំងមូល ។ អ្នកខ្លះមានការអប់រំខ្ពស់ ប៉ុន្តែអ្នកខ្លះពុំបានទទួលនូវការអប់រំខ្ពស់ទេ ។ ព្រះជាម្ចាស់ជ្រើសរើសពួកគាត់ម្នាក់ៗអោយតែងកណ្ឌគម្ពីរមួយ ឬច្រើននៅក្នុងព្រះគម្ពីរទាំងមូល ។ បងប្អូននឹងឃើញមានសិល្បៈវិធីច្រើនប្លែកៗពីគ្នានៅក្នុងព្រះគម្ពីរ ។ សិល្បៈវិធីខ្លះមានលក្ខណៈសាមញ្ញ ប៉ុន្តែខ្លះទៀតហាក់ដូចជាពិបាកយល់ ហើយខ្លះទៀតពោរពេញដោយគតិបណ្ឌិត ។

អ្នកតែងទាំងនេះសរសេររាល់ព្រះបន្ទូលដែលព្រះជាម្ចាស់គាប់ព្រះហឫទ័យអោយពួកគាត់សរសេរ ។ ពួកគាត់ជាមនុស្សដែលស្រឡាញ់ព្រះជាម្ចាស់ ហើយដើរតាមសេចក្ដីបង្រៀនរបស់ព្រះអង្គទៀតផង ប៉ុន្តែមិនមែនមានន័យថាពួកគាត់ល្អឥតខ្ចោះនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ ក៏យើងនៅតែអាចបញ្ជាក់ថា ព្រះគម្ពីរជាសេចក្ដីពិតមកពីព្រះជាម្ចាស់ ។ ព្រះគម្ពីរមានភាពត្រឹមត្រូវ និងពេញដោយសេចក្ដីពិត ។ មូលហេតុអ្វីទៅ? នេះមកពីការនិពន្ធព្រះគម្ពីរទាំងមូលស្ថិតនៅក្រោមការដឹកនាំរបស់ព្រះជាម្ចាស់ ហើយព្រះអង្គមិនបានធ្វេសប្រហែសឡើយ ។ ព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះជាម្ចាស់មកកាន់មនុស្ស ។ អ្វីទាំងអស់ដែលចែងនៅក្នុងនោះ សុទ្ធតែជាសេចក្ដីពិតទាំងអស់ ។ ព្រះយេស៊ូបានមានបន្ទូលយ៉ាងច្បាស់អំពីចំនុចនេះ នៅក្នុងសេចក្ដីអធិស្ឋានរបស់ព្រះអង្គនៅក្នុងកណ្ឌគម្ពីរយ៉ូហានជំពូកទី១៧ ។

**យ៉ូហាន ១៧:១៧** (ព្រះគម្ពីរជាភាសាខ្មែរបច្ចុប្បន្ន)

**សូមប្រោសគេអោយវិសុទ្ធ ដោយសារសេចក្ដីពិត គឺព្រះបន្ទូលរបស់ព្រះអង្គនោះហើយជាសេចក្ដីពិត។**

## គ. របៀបដែលព្រះគម្ពីរបានមកដល់យើង

### ១. តើកាលពីដំបូងកណ្ឌគម្ពីរបានសរសេរឡើងយ៉ាងដូចម្ដេច?

ក្រដាស់សៀវភៅនាពេលបច្ចុប្បន្ន មិនមានប្រើនៅរាប់ពាន់ឆ្នាំមុនក្នុងពេលដែលគេនិពន្ធព្រះគម្ពីរទេ ។ អ្នកតែងបានសរសេរកណ្ឌគម្ពីរទាំងអស់ឡើង នៅលើស្បែកសត្វដែលគេយកមកដេរជាប់គ្នាយ៉ាងវែង ហើយមូរទុក ។ គេហៅវាថា សំណៅលើស្បែកសត្វ ។

នៅសម័យនោះពុំមានការបោះពុម្ព ឬក៏កុំព្យូទ័រឡើយ ។ ដូច្នេះ កណ្ឌគម្ពីរទាំងអស់ត្រូវសរសេរឡើងដោយដៃ ។

ច្បាប់ដើមនៃព្រះគម្ពីរមិនមានសល់មកដល់សព្វថ្ងៃទេ។ ប៉ុន្តែកំណែនិមួយៗនៅក្នុងព្រះគម្ពីរត្រូវបានគេចំលងជាច្រើនពាន់ច្បាប់។ គេបានចំលងកំណែខ្លះ១០០ឆ្នាំក្រោយពេលការនិពន្ធបានចប់ជាស្ថាពរ។

**២. តើកំណែនៅក្នុងព្រះគម្ពីរទាំងមូលបានចំលងឡើងតាមវិធីណា?**

គេចំលងកំណែនៅក្នុងព្រះគម្ពីរដោយដៃ។ កាលពីនៅសម្ពន្ធមេត្រីចាស់ មានមនុស្សខ្លះបានស៊ីឈ្នួលជាអ្នកចំលងព្រះគម្ពីរ។ បទបញ្ជាក្នុងការចំលងព្រះគម្ពីរមានភាពតឹងរឹងជាខ្លាំង។ មិនអាចមានកំហុសក្នុងការចំលងបានឡើយ។ បើចំលងខុសតែបន្តិច អ្នកចំលងនោះត្រូវចាប់ផ្តើមចំលងសារឡើងវិញ ហើយត្រូវបោះច្បាប់ចំលងខុសនោះចោល។ បទបញ្ជាតឹងរឹងនេះពិតជាមានតំលៃខ្លាំងណាស់ ពីព្រោះបទបញ្ជានេះជួយអភិរក្សភាពត្រឹមត្រូវនៃការចំលងព្រះគម្ពីរបន្តវេងមក។

កំណែគម្ពីរភាគច្រើនដែលចំលងដោយដៃ មាននៅសល់មកទល់សព្វថ្ងៃនេះ។ កំណែចំលងខ្លះបានចំលងឡើងប្រហែល១០០ទៅ២០០ឆ្នាំមុនកំណើតព្រះគ្រិស្ត។ កំណែគម្ពីរចំលងទាំងនេះពិតជាមានតំលៃខ្លាំងណាស់។ ព្រះគម្ពីរជាភាសាអង់គ្លេសភាគច្រើន បានបកប្រែមកពីព្រះគម្ពីរជាភាសាហេប្រឺ និងភាសាក្រិក ដែលបានសរសេរនៅលើស្បែកសត្វ។

# ជំពូកទី៣

## តើយើងដឹងថាព្រះគម្ពីរមានភាពសុក្រឹតដោយរបៀបណា?

ព្រះគម្ពីរបានសរសេរឡើងតាំងពី២ ឬ៣ពាន់ឆ្នាំមុន ។ តើយើងអាចដឹងថាព្រះគម្ពីរមានភាពសុក្រឹតដោយរបៀបណា? តើយើងដឹងថាព្រះគម្ពីរជាសេចក្ដីពិតដោយរបៀបណា? តើយ៉ាងដឹងថាគ្មានការកែប្រែព្រះគម្ពីរដោយរបៀបណា? ប្រហែលជាមានកំហុសច្រើននៅក្នុងនោះ ។ តើយើងអាចដឹងថាគ្មានមនុស្សកែប្រែព្រះគម្ពីរដោយរបៀបណា?

តាមពិតមានចំនុចជាច្រើនដែលយើងអាចមើលឃើញភស្តុតាង ដែលបញ្ជាក់ថាព្រះគម្ពីរនាពេលបច្ចុប្បន្នមានភាពសុក្រឹត ត្រឹមត្រូវ និងជាសេចក្ដីពិត ។ យើងអាចមានទំនុកចិត្តថា ព្រះគម្ពីរមានចែងតែសេចក្ដីពិតប៉ុណ្ណោះ ។

### ក. គ្រប់ការថ្លែងព្រះបន្ទូលតាមរយៈព្យាការីសុទ្ធតែជាសេចក្ដីពិត ហើយត្រឹមត្រូវទៀតផង

ការថ្លែងព្រះបន្ទូលមានអត្ថន័យពីរគឺ:

（១） ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលថ្លែងតាមរយៈគ្រិស្តបរិស័ទ ។

（២） ការថ្លែងព្រះបន្ទូល-ជាព្រះបន្ទូលមកពីព្រះជាម្ចាស់ដែលថ្លែងអំពីហេតុការណ៍ដែលនឹងកើតមានឡើងនៅអនាគតកាល ។

ព្រះគម្ពីរមានចែងការថ្លែងព្រះបន្ទូលជាច្រើន ។ ចាប់ពីលោកុប្បត្តិជំពូកទី៣រហូតដល់ចុងបញ្ចប់នៃកណ្ឌគម្ពីរវិវរណៈ ព្រះជាម្ចាស់បានប្រទានអោយមនុស្សនូវរាជសារ និងការថ្លែងព្រះបន្ទូលជាច្រើន ។ មិនមែនមានតែព្យាការីម្នាក់ទេ គឺមានព្យាការីជាច្រើននៅក្នុងព្រះគម្ពីរបានថ្លែងអំពីការមកដល់របស់ព្រះយេស៊ូ ។ ការថ្លែងព្រះបន្ទូលរបស់ព្យាការីទាំងនោះបានក្លាយជាកាពិត ដោយសារនេះជាបន្ទូលរបស់ព្រះជាម្ចាស់ ។ អេសាយជំពូកទី៥៣ និង ទំនុកតម្កើងជំពូកទី២២ បានថ្លែងប្រាប់ជាមុនអំពីព្រះយេស៊ូ ។ សូមអានផងដែរនៅព្រះគម្ពីរ ម៉ាថាយ ៥:១៧-១៨ យេរេមា ២៨:៩ និង លូកា ២១:២៤ ។

នៅមានការថ្លែងព្រះបន្ទូលជាច្រើនទៀតដែលមិនទាន់កើតឡើង ។ ភាគច្រើនគឺការថ្លែងព្រះបន្ទូលចំពោះការយាងមកជាលើកទី២របស់ព្រះយេស៊ូ ។ ប្រសិនបើការថ្លែងព្រះបន្ទូលមួយចំនួនបានកើតឡើងរួចហើយ យើងក៏អាចមានទំនុកចិត្តថា ព្រះជាម្ចាស់ក៏នឹងបំពេញការថ្លែងព្រះបន្ទូលទាំងប៉ុន្មានដែលនៅសល់ផងដែរ ។ ការថ្លែងព្រះបន្ទូលដែលនៅសល់នោះគឺការយាងត្រឡប់មកជាលើកទី២របស់ព្រះយេស៊ូ ។

### ខ. ព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះជាម្ចាស់

មនុស្សដែលសរសេរព្រះគម្ពីរឡើង បានអះអាងថាស្នាដៃនេះជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ ព្រះជាម្ចាស់បានដឹកនាំហើយប្រាប់ពួកគេអោយសរសេរ ។ អ្នកតែងព្រះគម្ពីរទាំងអស់បានថ្វាយព្រះកិត្តិយសដល់ព្រះជាម្ចាស់ចំពោះស្នាដៃដែលពួកគេសរសេរ ។

២ធីម៉ូថេ ៣:១៦

២ពេត្រុស ១:២០-២១

### គ. ព្រះយេស៊ូមានបន្ទូលថា ព្រះគម្ពីរជាព្រះបន្ទូលរបស់ព្រះជាម្ចាស់

កាលព្រះយេស៊ូបានយាងមកផែនដីនេះ ព្រះអង្គមានព្រះបន្ទូលជាច្រើនលើកថា ព្រះគម្ពីរដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺជាសេចក្ដីពិត ។ ព្រះយេស៊ូបានបង្ហាញពីជំនឿរបស់ព្រះអង្គចំពោះព្រះគម្ពីរ ដោយប្រណិបត្តិជារៀងរាល់ថ្ងៃតាមសេចក្ដីបង្រៀននៅក្នុងព្រះគម្ពីរ ។

យ៉ូហាន ១៧:១៧

យ៉ូហាន ១០:៣៥

ម៉ាថាយ ៥:១៧-១៨

ប្រសិនបើព្រះគម្ពីរមិនមែនជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងមិនមែនជាសេចក្តីពិត នោះព្រះយេស៊ូមានបន្ទូលកុហកហើយនៅក្នុង យ៉ូហាន ១៧:១៧។ បើព្រះយេស៊ូកុហក នោះមានន័យថាព្រះអង្គបានប្រព្រឹត្តអំពើបាប។ បើព្រះយេស៊ូប្រព្រឹត្តអំពើបាប ការសុគតរបស់ព្រះអង្គនៅលើឈើឆ្កាងមិនអាចលោះអំពើបាបរបស់យើងបានឡើយ។ ប៉ុន្តែសូមអានខគម្ពីរខាងក្រោម ហើយពិចារណាអំពីសំដីរបស់ពួកគេ ដែលបាននិយាយអំពីព្រះយេស៊ូ។

ហេប្រឺ ៤:១៥

ហេប្រឺ ៩:៨-៩

១ពេត្រុស ៣:១៨

## ឃ. គ្មានបដិវាទកម្ម (ចំនុចដើរផ្ទុយគ្នា) នៅក្នុងព្រះគម្ពីរទាល់តែសោះ

អ្វីទៅជាបដិវាទកម្ម?

វាកើតឡើងនៅពេលមានចំនុចពីរ ហើយស្តាប់ទៅហាក់ដូចជាចំនុចទាំងពីរសុទ្ធតែត្រឹមត្រូវ ប៉ុន្តែចំនុចទាំងពីរនេះដើរផ្ទុយគ្នាទាំងស្រុង។ ដូច្នេះបើមួយជាសេចក្តីពិត មួយទៀតមិនមែនជាសេចក្តីពិតទេ។ ឧទាហរណ៍: ចំនុចមួយចែងថា"ផ្លែងាប់" ចំនុចមួយទៀតចែងថា "ផ្លែរស់"។ បើគេថាផ្លែងាប់ ផ្លែនោះមិនអាចរស់បានទេ។ ផ្លែនោះមិនអាចរស់ផង និងងាប់ផងបានទេ។

ព្រះគម្ពីរគ្មានបដិវាទកម្ម(ចំនុចដើរផ្ទុយគ្នា) ទាល់តែសោះ។ ព្រះគម្ពីរមិនបានចែងទេថា "ព្រះជាម្ចាស់ជាព្រះដែលស្លាប់រួចហើយ" ហើយនៅកន្លែងផ្សេងមួយទៀតបែរជាចែងថា "ព្រះជាម្ចាស់ជាព្រះដែលមានព្រះជន្មគង់នៅ"។ ជួនកាលអាចមានបដិវាទកម្មកើតឡើងមែននៅក្នុងព្រះគម្ពីរ ប្រសិនបើអ្នកដកស្រង់មើលតែឃ្លាមួយនៅក្នុងខមួយ ហើយមិនបានស្វែងយល់ពីអត្ថន័យរបស់ខ ឬជំពូកនោះទាំងមូល។

## ង. ភស្តុតាងខាងផ្នែកបុរាណវិទ្យា

ការសិក្សារបស់បុរាណវិទ្យាបានផ្តល់អោយយើងនូវ ភស្តុតាងកាន់តែសុក្រឹតថែមទៀតចំពោះព្រះគម្ពីរ។ អ្វីទៅជាបុរាណវិទ្យា? មានវចនានុក្រមមួយអោយនិយមន័យថា: "ជាវិទ្យាសាស្ត្រ ឬការសិក្សាអំពីជីវិតពីអតីតកាល និងអំពីប្រវត្តិសាស្ត្រ ដោយការជីករកទីក្រុងប្រាសាទចាស់ៗ ឬក៏វត្ថុផ្សេងៗដែលមានសល់ពីសម័យមុន។ (the Courtis-Walter Illustrated Golden Dictionary for Young Readers, Golden Press)

**១. បុរាណវិទូបានចំណាយពេលច្រើនឆ្នាំ ក្នុងការជីកនិងសិក្សាទីក្រុងចាស់ៗដែលមានសល់តាំងពីសម័យគេតែងព្រះគម្ពីរ**

មានសៀវភៅរាប់រយមានសរសេរអំពីការសិក្សាស្រាវជ្រាវផ្នែកបុរាណវិទ្យា ដែលផ្តោតទៅលើប្រធានបទផ្សេងៗពីគ្នា។ សេចក្តីពិតនៅក្នុងព្រះគម្ពីរសុទ្ធតែត្រឹមត្រូវ។ គ្មានបុរាណវិទូណាម្នាក់អាចបញ្ជាក់ថាព្រះគម្ពីរខុសនោះទេ តែពួកគាត់បែរជាអាចបញ្ជាក់ពីការពិតអំពី ទីក្រុង មហាក្សត្រនានា និង ប្រពៃណីនៅក្នុងព្រះគម្ពីរទៅវិញ។

### ២. សំណៅលើស្បែកសត្វនៅសមុទ្រមរណៈ

សំណៅលើស្បែកសត្វដែលរកឃើញនៅសមុទ្រមរណៈជាការស្រាវជ្រាវផ្នែកបុរាណវិទ្យាដ៏សំខាន់មួយ នៅសតវត្សទី២០។ គេរកឃើញសំណៅលើស្បែកសត្វនេះនៅឆ្នាំ១៩៤៧ នៅដែនដីមួយដែលសព្វថ្ងៃនេះគេហៅថាប្រទេសអ៊ីស្រាអែល។ សំណៅនិមួយៗមានសរសេរកណ្ឌគម្ពីរទាំឡាយ នៅក្នុងសម្ពន្ធមេត្រីចាស់ លើកលែងតែកណ្ឌមួយប៉ុណ្ណោះ។ សំណៅលើស្បែកសត្វដែលរកឃើញមុនៗភាគច្រើន បានសរសេរ

ឡើងចន្លោះ១០០ ទៅ២០០ឆ្នាំមុនកំណើតព្រះយេស៊ូ ។ ប៉ុន្តែសំណៅដែលចែងអំពីកណ្ឌគម្ពីរនៃសម្ពន្ធមេត្រីចាស់ទាំងអស់នេះ មានចំណាស់ចាស់ជាងសំណៅលើស្បែកសត្វមុន១ដល់ទៅ១០០០ឆ្នាំ ។

នៅពេលគេដាក់សំណៅលើស្បែកសត្វដែលរកឃើញនៅសមុទ្រមរណៈ ផ្ទឹមជាមួយនឹងព្រះគម្ពីរនាពេលបច្ចុប្បន្ន គ្មានចំនុចខុសគ្នាណាមួយដែលគួរអោយកត់សំគាល់នោះឡើយ ។ សំណៅលើស្បែកសត្វនៅសមុទ្រមរណៈជាភស្តុតាងដ៏សំខាន់មួយ ដែលបញ្ជាក់ថាព្រះគម្ពីរនាពេលបច្ចុប្បន្នមានភាពសុក្រឹត អាចជឿបាន ។ ហើយសំណៅទាំងនេះអាចអោយយើងមានទំនុកចិត្តថា ព្រះគម្ពីរនាពេលបច្ចុប្បន្នជាសំណៅតែមួយជាមួយនឹងកណ្ឌគម្ពីរដែលព្រះជាម្ចាស់បំភ្លឺមនុស្សសម័យមុនអោយសរសេរ ។

## ច. ភស្តុតាងខាងផ្នែកវេជ្ជសាស្ត្រ

មានការសិក្សាស្រាវជ្រាវជាច្រើនដែលបានធ្វើឡើង ដើម្បីបញ្ជាក់ថា ទ្រឹស្តីវេជ្ជសាស្ត្រដែលមាននៅក្នុងព្រះគម្ពីរ មានភាពត្រូវគ្នាជាមួយនឹងទ្រឹស្តីវេជ្ជសាស្ត្រនាពេលបច្ចុប្បន្ន ( មានការរកឃើញថ្មីៗបន្ថែមទៀត) ។

មានសៀវភៅមួយមានចំណងជើងថា *None of These Diseases* និពន្ធឡើងដោយលោកវេជ្ជបណ្ឌិត អេស អាយ ម៉ាមីឡិន ដែលជាវេជ្ជបណ្ឌិតផ្នែកវេជ្ជសាស្ត្រ ។ លោកបានបកស្រាយ និងពិភាក្សាទៅលើទ្រឹស្តីវេជ្ជសាស្ត្រជាច្រើន ដែលមានចែងនៅក្នុងព្រះគម្ពីរ ។ ហើយលោកបានបង្ហាញយ៉ាងច្បាស់អំពី ភាពត្រឹមត្រូវ និងភាពត្រូវគ្នារវាងទ្រឹស្តីវេជ្ជសាស្ត្រនៅក្នុងព្រះគម្ពីរ ជាមួយនឹងទ្រឹស្តីវេជ្ជសាស្ត្រក្នុងពេលបច្ចុប្បន្ន។

## ឆ. ធ្វើការបញ្ជាក់ដល់ខ្លួនឯងថា ព្រះគម្ពីរជាសេចក្តីពិត ដោយសាកល្បងអនុវត្តតាមសេចក្តីបង្រៀនរបស់ព្រះគម្ពីរនៅក្នុងជីវិតរបស់ខ្លួនផ្ទាល់

ប្រសិនបើសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរជាសេចក្តីពិត ហើយបើបងប្អូនអនុវត្តសេចក្តីបង្រៀនទាំងនោះនៅក្នុងជីវិតរបស់បងប្អូនជារៀងរាល់ថ្ងៃ នោះការផ្លាស់ប្រែនឹងកើតមានឡើង ។ ប៉ុន្តែបើសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរមិនមែនជាសេចក្តីពិតវិញនោះ នឹងគ្មានអ្វីកើតឡើងនៅក្នុងជីវិតរបស់បងប្អូនទាំងអស់ ជាពិសេសនៅពេលដែលបងប្អូនអនុវត្តវានៅក្នុងជីវិតរបស់បងប្អូន ។

តាមពិតមានមនុស្សរាប់លាននាក់បានអនុវត្តរួចហើយ ។ ពួកគេបានសាកល្បងដោយផ្ទាល់ជាមួយនឹងសេចក្តីបង្រៀនដែលមាននៅក្នុងព្រះគម្ពីរ ហើយជាលទ្ធផល ការផ្លាស់ប្រែនៅក្នុងជីវិតបានកើតឡើងប្រាកដមែន ។ សូម្បីតែនៅក្នុងព្រះគម្ពីរក៏បានបង្ហាញយើងអំពី ភស្តុតាងនៅក្នុងជីវិតរបស់មនុស្សជាច្រើន ដែលបានបញ្ជាក់ថាសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរជាសេចក្តីពិត ។

**ម៉ាកុស ១៦:២០ (ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន)**

**ពួកសិស្សនាំគ្នាចេញទៅប្រកាសដំណឹងល្អ នៅគ្រប់ទីកន្លែង។ ព្រះអម្ចាស់ធ្វើការរួមជាមួយគេ ទាំងបញ្ជាក់ព្រះបន្ទូលដោយសំដែងទីសំគាល់ផ្សេងៗជាប់ជាមួយផង។**

បែបនេះជាព្រឹត្តិការណ៍ដ៏សែនរំភើបមួយដែលបញ្ជាក់ដល់ខ្លួនរបស់បងប្អូនផ្ទាល់ថា សេចក្តីបង្រៀននៅក្នុងព្រះគម្ពីរជាសេចក្តីពិត ។

ម៉ាឡាគី ៣:១០

កូឡូស ១:៥-៦

យ៉ូហាន ៧:១៦-១៧

# ជំពូកទី៤
# ការសិក្សាខ្លីៗនៅលើសម្ពន្ធមេត្រីចាស់

គេបែងចែកព្រះគម្ពីរជាពីរផ្នែក ហើយផ្នែកនិមួយៗគេហៅថា សម្ពន្ធមេត្រី។ សម្ពន្ធមេត្រីជាការសន្យា កិច្ចព្រមព្រៀង ឬក៏ការចងមេត្រីភាព។ ព្រះគម្ពីរគឺជាការចងមេត្រីភាពរវាងព្រះជាម្ចាស់ជាមួយនឹងយើងទាំងអស់គ្នា។

សម្ពន្ធមេត្រីចាស់ត្រូវបានផ្តល់អោយជនជាតិយូដា។ នៅក្នុងនោះមានចែងអំពីហេតុការណ៍ ដែលបានកើតឡើងតាំងពីពេលព្រះជាម្ចាស់បង្កើតពិភពលោក រហូតដល់ជាង៤០០ឆ្នាំមុនកំណើតព្រះយេស៊ូ។ សម្ពន្ធមេត្រីចាស់មានចែងអំពីទំនាក់ទំនងរបស់ព្រះជាម្ចាស់ជាមួយមនុស្សមុនពេលព្រះយេស៊ូយាងមក។ ៧៥ភាគរយនៃព្រះគម្ពីរទាំងមូលជាសម្ពន្ធមេត្រីចាស់។ ហើយគេបានសរសេរសម្ពន្ធមេត្រីចាស់ឡើងជាភាសាហេប្រឺ។ មានតែពីរបីផ្នែកទេ ដែលគេសរសេរឡើងជាភាសាអារ៉ាម៉ាអ៊ិក។

នៅក្នុងសម្ពន្ធមេត្រីថ្មី ព្រះជាម្ចាស់មានបន្ទូលប្រាប់យើងអំពីហេតុផលដែលព្រះអង្គប្រទានសម្ពន្ធមេត្រីចាស់ដល់យើង។

**១កូរិនថូស ១០:១១** (ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន)

**ហេតុការណ៍ទាំងនេះកើតមានដល់ពួកលោក ទុកជាមេរៀន ហើយមានចែងទុកក្នុងគម្ពីរ ដើម្បីទូន្មានពួកយើងដែលរស់នៅជំនាន់ចុងក្រោយបង្អស់នេះ។**

មានខគម្ពីរចំនួនពីរផ្សេងទៀតដែលបំភ្លឺយើងអោយកាន់តែច្បាស់ថែមទៀតថា ព្រះជាម្ចាស់ពិតជាបានផ្តល់តំលៃយ៉ាងខ្លាំងទៅលើព្រះគម្ពីរសម្ពន្ធមេត្រីចាស់។

**២ធីម៉ូថេ ៣:១៦-១៧** (ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន)

គ្រប់អត្ថបទគម្ពីរ សុទតែព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកបំភ្លឺអោយតែង និង មានប្រយោជន៍សំរាប់បង្រៀន រកខុសត្រូវ កែតម្រង់ និង អប់រំអោយរស់តាមសេចក្តីសុចរិត ក្នុងគោលបំណងអោយអ្នកបំរើរបស់ព្រះជាម្ចាស់ មានសមត្ថភាព និង ប្រុងប្រៀបខ្លួនជាស្រេច ដើម្បីប្រព្រឹត្តអំពើល្អគ្រប់ជំពូក។

ហេប្រឺ ៤:១២ (ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន)

ដ្បិតព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាព្រះបន្ទូលដ៏មានជីវិត និង មានមហិទ្ធិឫទ្ធិមុតជាងដាវមុខពីរទៅទៀត។ ព្រះបន្ទូលនេះចាក់ទម្លុះចូលទៅកាត់ព្រលឹង និង វិញ្ញាណដាច់ចេញពីគ្នា កាត់សន្លាក់ឆ្អឹង និង ខួរឆ្អឹងចេញពីគ្នា។ ព្រះបន្ទូលវិនិច្ឆ័យឆន្ទៈ និង គំនិតនៅក្នុងជំរៅចិត្តមនុស្ស។

# ភាគទាំង៥នៅក្នុងសម្ពន្ធមេត្រីចាស់

**គម្ពីរបញ្ញត្តិ ឬ គម្ពីរវិន័យ**

(គម្ពីរសរសេរឡើងដោយលោកម៉ូសេ)

លោកុប្បត្តិ

និក្ខមនំ

លេវីវិន័យ

ជនគណនា

ទុតិយកថា

**គម្ពីរប្រវត្តិសាស្ត្រ**

យ៉ូស្វេ

ចៅហ្វាយ

នាងរស់

សាំយូអែល ទី១

សាំយូអែល ទី២

ពង្សាវតារក្សត្រ ទី១

ពង្សាវតារក្សត្រ ទី២

របាក្សត្រ ទី១

របាក្សត្រ ទី២

អែសរ៉ា

នេហេមា

អេសធើរ

**គម្ពីរកំណាព្យ**

យ៉ូប

ទំនុកតម្កើង

សុភាសិត

សាស្ដា

បទចំរៀងព្រះបាទសាឡូម៉ូន

**គម្ពីរព្យាការីខ្នាតវែង**

អេសាយ

យេរេមា

បរិទេវ

អេសេគាល

ដានីយ៉ែល

**គម្ពីរព្យាការីខ្នាតខ្លី**

ហូសេ

យ៉ូអែល

អេម៉ុស

អូបាឌា

យ៉ូណាស

មីកា

ណាហ៊ូម

ហាបាគូក

សេផានា

ហាកាយ

សាការី

ម៉ាឡាគី

# ជំពូកទី៥

# ការសិក្សាខ្លីៗទៅលើសម្ពន្ធមេត្រីថ្មី

កណ្ឌគម្ពីរទាំង២៧នៅក្នុងសម្ពន្ធមេត្រីថ្មីមានចែងប្រាប់យើងអំពី ជីវិតរបស់ព្រះយេស៊ូ និងហេតុការណ៍ដែលបានកើតឡើងបន្ទាប់ពីព្រះអង្គបានយាងទៅស្ថានបរមសុខវិញ។ កណ្ឌគម្ពីរភាគច្រើនបានចែងអំពីកិច្ចការដែលសាវ័ករបស់ព្រះយេស៊ូ និងលោកប៉ូលបានបំពេញ។

សូមអានសេចក្តីសង្ខេបសម្ពន្ធមេត្រីថ្មី នៅក្នុងសៀវភៅដែលមានចំណងជើងថា ***យល់ដឹងពីព្រះគម្ពីររបស់ខ្លួន***។ ហើយខាងក្រោមនេះជាបញ្ជីកណ្ឌ និងការបែងចែកនៅក្នុងសម្ពន្ធមេត្រីថ្មី។

## ភាគទាំង៥នៅក្នុងសម្ពន្ធមេត្រីថ្មី

**គម្ពីរដំណឹងល្អ**

ម៉ាថាយ

ម៉ាកុស

លូកា

យ៉ូហាន

**ប្រវត្តិសាស្ត្រក្រុមជំនុំ**

កិច្ចការរបស់សាវ័ក

**លិខិតរបស់លោកប៉ូល**

រ៉ូម

កូរិនថូស ទី១

កូរិនថូស ទី២

កាឡាទី

អេភេសូ

ភីលីព

កូឡូស

ថេស្សាឡូនិក ទី១

ថេស្សាឡូនិក ទី២

ធីម៉ូថេ ទី១

ធីម៉ូថេ ទី២

ទីតុស

ភីលេម៉ូន

**លិខិតផ្សេងៗ**

ហេព្រើ

យ៉ាកុប

ពេត្រុស ទី១

ពេត្រុស ទី២

យ៉ូហាន ទី១

យ៉ូហាន ទី២

យ៉ូហាន ទី៣

យូដាស

**គម្ពីរព្រះបន្ទូលថ្លែងទុក**

វិវរណៈ